គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# មតិស្វាគមន៍ និងរបាយការណ៍
# សម្រាប់ទិវាជាតិ ១២ធ្នូ លើកទី១៦ ឆ្នាំ២០២២
# នៅសាលមហោស្រព និងពិព័រណ៍កោះពេជ្រ

ដោយលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

- សូមថ្វាយបង្គំ ព្រះរាជាគណៈសង្ឃ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ
- សូមគោរព **សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាដ៏ឧត្តុង្គ ឧត្តម នៃព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល លោកឧកញ៉ា អ្នកឧកញ៉ា ឯកឧត្តម លោកជំទាវ បណ្ឌិតសភាចារ្យ សាស្ត្រាចារ្យ បញ្ញាវ័ន្ត អាជ្ញាធររាជធានីខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ស្ថានតំណាង កុងស៊ុល ប្រចាំនៅកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធាន ឬតំណាងអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល
- តំណាងគ្រប់និកាយសាសនា សិស្ស និស្សិត បងប្អូន ក្មួយៗ ជនរួមជាតិទាំងមូល ជាទីគោរព រាប់អាន

ជាបឋម ក្នុងនាមនាងខ្ញុំជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្នុងនាមគណៈកម្មការរៀបចំកម្មវិធី នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមគោរពថ្លែងអំណរគុណ និងសូមគោរពស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចក្រឡាហោម នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា** ដែលបានផ្តល់នូវកិត្តិយសដ៏ខ្ពង់ខ្ពស់អញ្ជើញជាអធិបតី ក្នុងពិធី ទិវាជាតិ១២ធ្នូប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០២២ ក្រោមប្រធានបទ «រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ប្រកបដោយចីរភាព» ដែលបានប្រារព្ធធ្វើយ៉ាងអធឹកអធម នាថ្ងៃនេះ ។ នាងខ្ញុំ ក៏សូមគោរពថ្លែងអំណរព្រះគុណ ចំពោះ ព្រះវត្តមាន ព្រះរាជាគណៈសង្ឃ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ និងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមាន ឯកឧត្តម លោកជំទាវ ឥស្សរជន

ជាន់ខ្ពស់នៃព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល តំណាងអង្គទូត និងស្ថានតំណាងនានា នៃបណ្តាប្រទេសជាមិត្ត តំណាងអង្គការសហប្រជាជាតិ ប្រចាំនៅកម្ពុជា ភ្ញៀវជាតិ និងអន្តរជាតិ ដែលរួមមាន ឯកឧត្តម លោកជំទាវ បណ្ឌិតសភាចារ្យ លោកឧកញ៉ា អ្នកឧកញ៉ា សាស្ត្រាចារ្យ និស្សិត បញ្ញវន្ត តំណាងនិកាយសាសនានានា សិស្សានុសិស្ស កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ពីទីបញ្ជាការដ្ឋានកងទ័ពជើងទឹក ជើងគោក ជើងអាកាស នៃក្រសួងការពារជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស កងកម្លាំងនគរបាល គ្រប់ប្រភេទ អង្គភាពដោះមីន *CMAC* កងកម្លាំងរក្សាសន្តិសុខអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ វិស័យឯកជន យុវជន យុវនារី សសយក កាកបាទក្រហម កាយរឹទ្ធ ជាសមាជិក សមាជិកា នៃអង្គពិធីដ៏មានសារៈសំខាន់នាថ្ងៃនេះ ដែលមានចំនួនសរុប ជាង ៣០០០អង្គ/នាក់ ។

នេះជាឆ្នាំទី១៦ ហើយ បន្ទាប់ពីរាជរដ្ឋាភិបាល បានសម្រេចយកថ្ងៃទី **១២ ខែធ្នូ** ជាទិវាជាតិប្រឆាំងការជួញដូរមនុស្សពីឆ្នាំ២០០៧ ដែលលើកទី១ បានប្រារព្ធធ្វើនៅទីលានវាលហាង្សមុខវត្តបុទុម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ក្នុងឆ្នាំ២០០៧ ហើយដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានរៀបចំព្រឹត្តិការណ៍ដ៏មានសារសំខាន់នេះបន្ត ក្នុងឆ្នាំ២០១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** និងបន្តរហូតមកដល់បច្ចុប្បន្ន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ។ កម្មវិធីជួបជុំទ្រង់ទ្រាយធំបែបនេះ ត្រូវបានផ្អាករយៈពេល ២ឆ្នាំ គឺក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ ដែលកម្ពុជា កំពុងស្ថិតក្នុងស្ថានភាព នៃការរាតត្បាត ដោយជំងឺកូវីដ-១៩ តែបានរៀបចំជាការផ្សព្វផ្សាយ ជាបទយកការណ៍ និងបញ្ជូនសារផ្សេងៗ ដោយមានការចាក់បញ្ចាំងតាមគ្រប់ស្ថានីយ៍ផ្សព្វផ្សាយ នៅទូទាំងប្រទេស និងនៅក្នុងបណ្តាញសង្គមនានា ។

ក្នុងឆ្នាំ២០២២ នេះ ក្រោមនយោបាយ «ចាក់ស្រោចវ៉ាក់សាំង» របស់រាជរដ្ឋាភិបាលកម្ពុជា ដែលប្រជាពលរដ្ឋ ចាប់ពីអាយុ ៣ឆ្នាំឡើងទៅ ដល់ចាស់ជរា ទាំងខ្មែរទាំងបរទេស រស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា បានទទួលវ៉ាក់សាំងដោយឥតគិតថ្លៃ ទាំង ដូសមូលដ្ឋាន ទាំងដូសជំរុញ រួមជាមួយនឹងការអនុវត្តវិធានការ «បីកុំ បីការពារ មួយចូលរួម» និងការកាត់ផ្តាច់ចរន្ត នៃការឆ្លងទៅសហគមន៍ បានធ្វើឱ្យព្រះរាជាណាចក្រកម្ពុជា បានឆ្លងផុតដំណាក់កាល ដែលប្រឈមខ្លាំង និងវិលមករកប្រក្រតីភាពតាមគន្លងថ្មីឡើងវិញ ហើយក៏គ្មានអ្នកស្លាប់ថ្មី ដោយកូវីដ-១៩ ដែរ ក្នុងរយៈពេលបួនខែកន្លងមកនេះ ។

ឆ្លៀតក្នុងបរិយាកាសដ៏ល្អប្រសើរនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមសហការជាមួយដៃគូពាក់ព័ន្ធ ជាតិនិងអន្តរជាតិ បានជំរុញអនុវត្ត

យុទ្ធសាស្ត្រទាំងបួន ដែលបានគ្រោងទុកក្នុងផែនការ រួមមាន៖ **ការបង្ការទប់ស្កាត់ កិច្ចការពារជនរងគ្រោះ ការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងកិច្ចសហប្រតិបត្តិការ** ផ្នែកច្បាប់ និងគោលនយោបាយប្រឆាំងការជួញដូរមនុស្ស ។

ការបង្កើនសកម្មភាពអប់រំផ្សព្វផ្សាយ ត្រូវបានធ្វើឡើងតាមគ្រប់មធ្យោបាយ មានជាអាទិ៍ ការផ្សព្វផ្សាយតាមកម្មវិធីវិទ្យុ ទូរទស្សន៍ ប្រព័ន្ធបណ្តាញសង្គម ដោយផលិតបទយកការណ៍ចំនួនបី សន្និសីទសារព័ត៌មាន និពន្ធបទចម្រៀងដែលមានសារអប់រំ បទសម្ភាសន៍ ការផលិតសម្ភារៈអប់រំដទៃទៀត ដើម្បីចែកផ្សាយ ការរៀបចំព្រឹត្តិការណ៍សុវត្ថិភាពអ៊ីនធឺណិត សម្រាប់កុមារ និងយុវវ័យ ការរៀបចំវេទិកាជាតិអន្តរសាសនា ព្យុហយាត្រាឆ្ពោះទៅលុបបំបាត់អំពើជួញដូរមនុស្ស(ខេត្តសៀមរាប) ការចុះផ្សព្វផ្សាយអប់រំតាមវេទិកាសាធារណៈ នៃគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ។ល។ និងបានរៀបចំទិវាជាតិ **១២ ធ្នូ** ប្រឆាំងការជួញដូរមនុស្ស ដូចដែលបានប្រារព្ធធ្វើឡើង ក្នុងថ្ងៃនេះជាដើម ហើយនឹងត្រូវបន្តរៀបចំតាមបណ្តាខេត្តទូទាំងប្រទេស ។ គិតក្នុងរយៈពេល ១០ខែកន្លងមកនេះ តាមរបាយការណ៍ពីក្រសួង ស្ថាប័នរាជធានី-ខេត្ត និងអង្គការដៃគូ ចុះអប់រំផ្សព្វផ្សាយផ្ទាល់ សរុបបានចំនួន ១០៦.៨២៦លើក មានអ្នកចូលរួមសរុបចំនួន ៤.៩៧២.៩៧០នាក់ ស្រី២.៦៤៨.៣៤៧នាក់។

កម្មវិធីវេទិកាជាតិអន្តរសាសនា ដែលត្រូវបានប្រារព្ធធ្វើនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ មានការចូលរួមពីនិកាយសាសនាធំៗ នៅកម្ពុជា ជាងប្រមាណ ១៥០០អង្គ/នាក់ និងត្រូវបាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសជាផ្លូវការកំណត់យក «**ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២ ជាទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស**» ចាប់ពីឆ្នាំ២០២៣តទៅ ។ វេទិកានេះ នឹងបន្តទៅផ្សព្វផ្សាយការអប់រំតាមសហគមន៍ទូទាំងប្រទេស ដោយបព្វជិត សាសនាគ្រប់និកាយ និងបានធ្វើការប្តេជ្ញាចិត្តរួមគ្នាដោយសេចក្តីប្រកាសរួម ចុះហត្ថលេខាដោយតំណាងនិកាយសាសនា ចំនួន ៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ឈិត សាខុន** រដ្ឋមន្ត្រីក្រសួង ធម្មការ និងសាសនា ។

ចំណែកវិស័យឯកជន ក៏បានរួមសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការអនុវត្តក្រមសីលធ៌មក្នុងការជ្រើសរើស និងបញ្ជូនពលករទៅបរទេស ដោយបានចុះហត្ថលេខាទទួលអនុវត្តសាកល្បង ប្រព័ន្ធវាយតម្លៃ ដោយក្រុមហ៊ុនឯកជន ចំនួន ១០ រួចហើយក្រោមគំនិតផ្តួចផ្តើមរបស់អង្គការពលកម្មអន្តរជាតិ ILO និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

រាជរដ្ឋាភិបាលកម្ពុជា បានខិតខំដោះស្រាយបញ្ហា ដែលជះឥទ្ធិពលពីវិបត្តិ កូវីដ-១៩ គួបផ្សំនឹងផលប៉ះពាល់ នៃវិបត្តិសេដ្ឋកិច្ចពិភពលោក និងគ្រោះធម្មជាតិ ដែលបានយាយី នៅគ្រប់ទីកន្លែង ជាពិសេស

ចំពោះការធ្វើសមាហរណកម្មពលករ ដែលបានវិលត្រឡប់ពីប្រទេសគោលដៅ ប្រមាណ **៣០ម៉ឺននាក់** ដែលភាគច្រើនជាអ្នក ដែលចាកចេញពីភូមិស្រុករយៈពេលយូរ ខ្វះលទ្ធភាពក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ ឱ្យទទួលបានស្ថានភាពល្អប្រសើរ មានការងារ មុខរបរជាប្រក្រតី និងទទួលបានសេវាសង្គមទាំងឡាយ ដូចប្រជាពលរដ្ឋដទៃទៀតដែរ ។

នៅក្នុងឆមាស ទី១ នៃឆ្នាំ២០២២ កន្លងទៅ ស្ថានភាព នៃអំពើជួញដូរមនុស្ស មានភាពល្អប្រសើរ ដោយអត្រានៃបទល្មើស បានថយចុះ គួរឱ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងឆ្នាំ២០២១ ។ នៅពេលដែលស្ថានភាពទូទៅ បានរៀបរយល្អប្រសើរហើយចំពោះសកម្មភាពបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ បែរជាកើតមានបទល្មើសថ្មី លើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ដែលបង្កឡើងដោយឧក្រិដ្ឋជនមួយចំនួន ដែលសម្ងំលាក់ខ្លួនប្រព្រឹត្តបទល្មើស ក្នុងអាជីវកម្មបន្លំក្លែក ដោយប្រើប្រាស់ឱកាសដ៏ល្អ ដែលរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងផ្តល់ឱ្យ សម្រាប់ការវិនិយោគដើម្បីការអភិវឌ្ឍន៍ នៅក្នុងតំបន់ប៉ូលសេដ្ឋកិច្ចធំៗ ដូចជា ខេត្តព្រះសីហនុ រាជធានីភ្នំពេញ ជាដើម និងបណ្តាខេត្តមួយចំនួនទៀត ទៅធ្វើសកម្មភាពឧក្រិដ្ឋប្រឆាំងនឹងសិទ្ធិមនុស្ស ។ ឧក្រិដ្ឋជន បានប្រព្រឹត្តសកម្មភាពឃោរឃៅទៅលើជនរងគ្រោះ ដោយ ពលកម្មដោយបង្ខំ ការឆបោកតាមប្រព័ន្ធអនឡាញ ការអូសទាញជនងាយរងគ្រោះពីក្រៅប្រទេសដើម្បីបង្ខំឱ្យបម្រើសកម្មភាពឆបោកខុសច្បាប់ និងឧក្រិដ្ឋកម្មផ្សេងៗទៀត ដែលភាគច្រើនដាច់ខាត ប្រព្រឹត្តដោយជនបរទេស ទៅលើជនបរទេសផងគ្នា និងមានបណ្តាញ ទាក់ទងគ្នាយ៉ាងសកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬអនឡាញ ប្រទាក់ក្រឡាពីប្រទេសមួយទៅប្រទេសមួយ ។

នេះជាភាពប្រឈមថ្មី ដែលរាជរដ្ឋាភិបាលកម្ពុជាមិនអាចព្រងើយកន្តើយបានឡើយ ហើយត្រូវឆ្លើយតបជាបន្ទាន់ តាមវិធានការបោសសម្អាតបទល្មើស យ៉ាងមានប្រសិទ្ធភាព នោះគឺ «ផែនការប្រតិបត្តិការបង្កើនការបង្ក្រាបអំពើជួញដូរមនុស្សគ្រប់ទំរង់ និងបទល្មើសពាក់ព័ន្ធ» តាមសេចក្តីសម្រេច របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លេខ ៤៣/២២ប្រក. ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០២២ និងបង្កើតក្រុមការងារប្រតិបត្តិការ ដឹកនាំដោយ អគ្គស្នងការនគរបាលជាតិ និងបើកយុទ្ធនាការនៅទូទាំងប្រទេស រុករកបទល្មើស បណ្តាញជនល្មើស និងសង្គ្រោះជនរងគ្រោះ នៅតាមទីតាំងដែលមានការសង្ស័យ យ៉ាងសកម្ម ។ ៦៧៦សំណើ ត្រូវបានដាក់ចូលក្នុងគេហទំព័រ ហ្វេសប៊ុក **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដោយផ្ទាល់ និងត្រូវបានស៊ើបអង្កេត និងបង្ក្រាបបទល្មើស ជាបន្តបន្ទាប់ ។ ជាលទ្ធផល គិតចាប់ពីថ្ងៃ ទី១៨ ខែសីហា មកដល់ខែវិច្ឆិកា ឆ្នាំ២០២២ កន្លងទៅ គឺក្នុងចំណោមអ្នកដែលបានប្រកាសថា ជាជនរងគ្រោះ សុំឱ្យធ្វើអន្តរាគមន៍

ជួយសង្គ្រោះ យើងបានរកឃើញមនុស្សចំនួន ១១២២នាក់ ស្រី ១២១នាក់ ហើយ តែក្នុងចំណោមជនទាំងនោះ អ្នកដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការបង្ខាំងខ្លួន និងពលកម្មដោយបង្ខំ ១៥៣នាក់ ស្រី១៨នាក់ មាន ០៦សញ្ជាតិ និងដោយអំពើ ចំណែកជនក្រៅពីនេះ បានបដិសេធថាខ្លួន មិនបានទទួលភាពរងគ្រោះទេ និងមានបំណងចង់ប្តូរទៅទីតាំងការងារថ្មីដែលមានប្រាក់ខែខ្ពស់ជាងនេះ ឬថា គ្រាន់តែជាការបារម្ភ របស់ក្រុមគ្រួសារតែប៉ុណ្ណោះ ។ ទោះបីជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវតែ នាំចេញពីទីតាំងដែលពាក់ព័ន្ធនឹងបទល្មើស ដើម្បីសុវត្ថិភាពពលករ និងមិនអនុញ្ញាតឱ្យវិលត្រឡប់ទៅកាន់ទីតាំងទាំងនោះវិញឡើយ ។ គិតពីចាប់ផ្តើមប្រតិបត្តិការ ដល់ត្រឹមថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ជនសង្ស័យ ២២នាក់ មានបីសញ្ជាតិ ដែលសង្ស័យពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស ២២នាក់ និងជនសង្ស័យពាក់ព័ន្ធនឹងអំពើជួញដូរផ្លូវភេទ ០៤នាក់ ០១ សញ្ជាតិ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីចាត់វិធានការ តាមនីតិវិធីច្បាប់កម្ពុជា ។ ទីតាំងសង្ស័យប្រព្រឹត្តបទល្មើស ចំនួន ៥ ត្រូវបានបិទជាស្ថាពរ និងបួនទីតាំងបិទបណ្តោះអាសន្នដើម្បីស្រាវជ្រាវរកបទល្មើស ។

ក្រោមវិសាលភាពនៃការអភិវឌ្ឍន៍រីកចម្រើន វិស័យសំណង់ហេដ្ឋារចនាសម្ព័ន្ធ វិស័យសេវាកម្ម វិស័យពាណិជ្ជកម្ម វិស័យឧស្សាហកម្ម វិស័យកសិកម្ម បរិស្ថាន និងការអភិវឌ្ឍន៍ជនបទ បានបង្កើនការងារឱ្យប្រជាពលរដ្ឋក្នុងស្រុករាប់សែននាក់ ។ ទន្ទឹមនឹងនោះ ប្រជាជនមួយចំនួន នៅតែមានបំណងចេញទៅរកការងារនៅក្រៅប្រទេសដោយប្រថុយប្រថាន មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឱ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់យ៉ាងធ្ងន់ធ្ងរ។

ពាក់ព័ន្ធនឹងកិច្ចសហការ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានផ្សារភ្ជាប់ទំនាក់ទំនងរវាងស្ថាប័នជាតិ និងអន្តរជាតិ ដោយសហការជាមួយប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងក្នុងពិភពលោក ក្នុងនាមជាប្រទេសក្នុងមហាអនុតំបន់មេគង្គ ជាសមាជិកអាស៊ាន សមាជិក SOMTC សមាជិកអនុសញ្ញាអន្តរជាតិ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន សមាជិកនៃកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ និងជាប្រទេសជ័យលាភី នៃគំនិតផ្តួចផ្តើមនៃកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ ។

ដើម្បីជូនជ្រាបបានកាន់តែច្បាស់ នូវស្ថានភាពនៃអំពើជួញដូរមនុស្ស នៅកម្ពុជា និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា សូមគោរពអញ្ជើញសម្តេច ឯកឧត្តម លោកជំទាវ ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ អញ្ជើញទស្សនាខ្សែវីដេអូបទយកការណ៍ខ្លី នៅពេលបន្តិចទៀតនេះ រួមជាមួយនឹងការសម្តែង

សិល្បៈ ដែលរួមសហការដោយទូរទស្សន៍បាយ័ន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងប្រសាសន៍សំណេះសំណាល ដឹកនាំ ណែនាំដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចក្រឡាហោម នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា** ក្នុងពេលបន្តបន្ទាប់ទៅនេះ ។

នាងខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមគាំទ្រពីអង្គការដៃគូ វិស័យឯកជន មួយចំនួន ដើម្បីបំពេញបន្ថែមក្នុងដំណើរការរៀបចំទិវាជាតិដ៏មានសារសំខាន់នេះ ដូចដែលមានរាយនាម ក្នុងតារាងដៃគូដែលបានជួយឧបត្ថម្ភគាំទ្រ ។

ជាទីបញ្ចប់ នាងខ្ញុំសូមគោរពប្រគេនពរព្រះបិរានុត្តេរៈគ្រប់ព្រះអង្គ សូមគោរពជូនពរ **សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិទាំងអស់** ជួបប្រទះតែពុទ្ធពរទាំង ០៤ប្រការ គឺអាយុ វណ្ណៈសុខៈពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរព្រះគុណ សូមអរគុណ